Reading Book

# ពិភពរឿងនិទាន

The World of Stories



# តាព្រហ្ម នៅវត្តនគរបាជ័យ

## Ta Prom at Nokorbachey Temple

M.75

សូមជួយថែរក្សាកេរមរតកជាតិខ្មែរ

បើយើងធ្វើដំណើរពីភ្នំពេញតាមផ្លូវជាតិ៦Aទៅដល់ទីប្រជុំជនស្គន់ បែកទៅតាមផ្លូវជាតិលេខ៧ទៅដល់ភ្នំប្រុសភ្នំស្រីខេត្តកំពង់ចាម ហួសបន្តិចទៅៗដល់រង្វង់មូលនាគព័ន្ធ មានផ្លូវលំមួយនៅខាងលិចប្រមាណជា៣០០ម៉ែត្រប៉ុណ្ណោះ។ មានកំពែងថ្មបាយក្រៀមប្រកបដោយខ្លោងទ្វារបាក់បែកជាច្រើន។ បរិវេនកំពែង នេះអ្នកស្រុកហៅថា **វត្តនគរបាជ័យ** ឬហៅកាត់ខ្លីថា "**វត្តនគរ**"។ បើចូលតាមផ្លូវខាងកើតនឹងដល់កំពែងមួយទៀតមានរោងទងតភ្ជាប់ជុំវិញ និងមានខ្លោងទ្វារជាបួនទិស។ ខ្លោងទ្វារនិងរោងទងនោះនៅល្អដោយអន្លើៗ តែមានអន្លើខ្លះបាក់បែកដែរ។ ចូលផុតពីនេះទៅនឹងដល់ខ្លោងទ្វារទី៣ដែលមានភ្ជាប់ទាំងរោងទងស្រឡះហើយនៅស្អាតនៅឡើយ បាក់ធ្លាក់តែកំពូលចុងតែប៉ុណ្ណោះ។ នៅចំកណ្ដាលរោងទងដែលមានខ្លោងទ្វារបែរទៅទិសធំទាំង៤ មានប្រាង្គណ៍មួយធំទទឹងម្ខាងទៅម្ខាង ខាងបាតក្រោមប្រមាណជា១៥ម៉ែត្ររាង៤ជ្រុងស្មើ កំពូលលើរាងស្រួចមានសណ្ឋានជាចេតិ។ ក្នុងប្រាង្គណ៍នេះមានព្រះពុទ្ធរូប៤អង្គ បែរព្រះភ័ក្ត្រតាមចន្លោះទ្វារឆ្ពោះទៅរកទិសធំទាំង៤ ។

នៅចន្លោះកំពែងជាន់ទី២ និងទី៣ ខាងត្បូងមានវិហារតូចៗពីរ ឯខាងជើងក៏មានពីរដែរ។ បណ្ដាវិហារតូចទាំង៤នេះមានវិហារមួយនៅទិសឦសានប្រាង្គណ៍ដំកល់ព្រះពុទ្ធរូប៤អង្គ គង់បែរព្រះភ័ក្ត្រទៅកាន់ទិសធំទាំង៤ ហើយព្រះបដិមាផ្អែកទៅនឹងចេតិយធំមួយនៅចំកណ្ដាល។

ពីខាងកើតចំនៃវិហារនោះ មានគុហារតូចមួយទៀតដំកល់រូបបដិមា៣អង្គ ពីរអង្គឈរកាន់ដំបងបញ្ឈរទំនងជាសេនា មួយអង្គទៀតអង្គុយពែនជើងលើអាសនៈខ្ពស់ ដៃប្រណម្យឆ្ពោះចំមករកចេតិយដែលពោលខាងលើ រូបភាពចម្លែកនេះហើយដែលមានរឿងនិទានមួយដំណាលតៗគ្នាមកថា ៖





If we traval on the National Road 6A from Phnom Penh to Skun town and National Road 7 to Phnom Bros Phnom Srey Mountains in Kompong Cham a bit far toward Neakporn Roundabout and approximately 300m on an unpaved road further to the west, there stand laterite walls with falling gopuras (gateways). The compound of the walls is called Wat Nokorbachey or "Wat Nokor" in short by the local villagers. Going through the eastern gateway, we will reach another wall section of surrounding corridor with four gateways facing the main directions. Among the gateways and corridors, some still stay magnificent while others collapse. Then passing through, we will get to the third section of the wall, whose corridor is spacious, elegant, only fallen down on the top. In the center of the corridor of each side gateway facing 4 main directions, stands a large tower with a square shape of 15m in each side and a stupa-shaped top. In the tower, there stay four Buddha statues facing the four main directions. Between the 2nd and the 3rd sections of the walls, two small temples are located in the south and the other two in the north. One of the 4 small temples, in the north-east shelters 4 Buddha statues lean against a large stupa facing the 4 main directions.

In the east of the temple, stands a small shrine with 3 statues; two gesturing holding the sticks upside down in a position resembling the guards and one in the middle sitting on a high stool with hands praying and facing the above-said stupa. The legend underlying the strange statue has been passed by words of mouth for a long time that:



អំឡុងជាយូរឆ្នាំកន្លងផុតទៅហើយ នៅប្រទេសកម្ពុជាមានស្ដេចត្រាញ់មួយព្រះអង្គជា **ព្រះអនុរាធ** បានយាងជ្រើសរើសរកទីកន្លែងសាងឧទ្យាន និង ព្រះរាជដំណាក់ដើម្បីទុកជាទីកំសាន្តលំហែព្រះចិន្តាក្នុងគ្រាដែលទ្រង់អផ្សុក។ ព្រះអង្គបានយាងមួយអន្លើជាមួយពួកសេនាអាមាត្យសព្វមុខមន្ត្រីសឹងតែគ្រប់ទីកន្លែងនៅក្នុងអាណាខេត្តដែលនៅក្នុងបន្ទុកព្រះអង្គត្រួតត្រា។ ថ្ងៃមួយ ក្បួនដង្ហែស្ដេចត្រាញ់បានមកដល់ព្រែកមួយនៅជាប់នឹងដងទន្លេធំសព្វថ្ងៃនេះជាទីក្រុងកំពង់ចាម ហើយពេលនោះមាន បណ្ដាជនជាច្រើនកំពុងរករបរចិញ្ចឹមជីវិតដោយធ្វើឆ្នោះ ព្រួល សម្រះ ចាប់ត្រីក្នុងព្រែកនោះ។ ព្រះអង្គ ទ្រង់ត្រាស់បង្គាប់ដល់កងយោធាឱ្យបោះជំរំ សង់ព្រះពន្លានៅទៀបនឹងមាត់ព្រែក ព្រោះទីនោះសំបូរដោយធម្មជាតិ និងមានខ្យល់អាកាសល្អ។

In the olden time, there lived a feudal lord (sdech tranh) in Cambodia named Preah Anuraja (or Lord Anuraja), who was on his journey in search of a suitable site for building a park and royal court to entertain himself while boredom. The lord traveled to almost all parts of his territory with his officials. One day, the parade of the lord arrived at a canal near a big river in today Kompong Cham city, while the local residents were fishing with barrage, sweeping net, and bar in the canal. He ordered his men to camp nearby area due to its wonderful nature and setting.





វេលានោះ **នាងពៅ**
ដែលជាម្ចាស់ផ្ទះ បានដឹងថា
**ព្រះអនុរាជ** យាងមកបោះព្រះពន្លាជ័យនៅ
ក្បែរកន្លែងខ្លួនដូច្នោះ ក៏ម្ទីម្ទាចាត់ចែងអស់ពួកបាវព្រាវ
ឱ្យរៀបចំព្រះក្រយាស្ងោយព្រមទាំងវត្ថុដ៏ប្រណិតផ្សេងៗ ហើយ
យកទៅថ្វាយព្រះអង្គ។ រៀបចំរួចរាល់ហើយ **នាងពៅ** ក៏ប្រោះព្រំអស់រាងកាយ
ឱ្យក្រអូបទៅដោយក្លិនខ្លឹមចន្ទន៍ ហើយស្លៀកពាក់យ៉ាងសមរម្យដើរល្វាសល្វន់ពីមុខស្រីបម្រើ។ ដៃនាងទាំងគូទ្រនូវពានគ្រឿងព្រះស្រី គេឃើញពន្លឺខ្សែដៃមាសពេជ្ររំលេចពណ៌ផ្លេកៗដេញរស្មីព្រះអាទិត្យ។ លុះទៅដល់ហើយ **នាងពៅ** ព្រមទាំងស្រីបម្រើក៏ឱនក្បាលក្រាបវន្ទាព្រះចេស្តាដោយពោលពាក្យក្រាបបង្គំទូលថា "សូមទ្រង់មេត្តាប្រោស ! ខ្ញុំម្ចាស់ទើបបានដំណឹងថា ព្រះអង្គយាងមកក្រសាលព្រះកាយនៅទីនេះ ទើបខ្ញុំម្ចាស់រៀបចំគ្រឿងជង្វាយទាំងនេះមកថ្វាយព្រះអង្គ សូមប្រោសព្រះរាជានុញ្ញាតដោយអនុគ្រោះ"។ ព្រះរាជាត្រាស់ថា "យើងរីករាយណាស់ដែលនាងមានចិត្តល្អនឹងខ្ញុំយ៉ាងនេះ សូមនាងលើកគ្រឿងជង្វាយមកចុះ"។ **នាងពៅ** ក៏លើកអស់គ្រឿងបណ្ណាការមកដាក់ចំពោះព្រះភ័ក្រព្រះអង្គ ហើយឱនក្បាលក្រាបបង្គំម្តងទៀតដោយវាចាថា "ខ្ញុំម្ចាស់សូមក្រាបបង្គំលា"។ ព្រះរាជាទ្រង់ញញឹម ហើយត្រាស់តបវិញថា "នាងទៅចុះ ! ចូរនាងឧស្សាហ៍មកលេងនឹងយើងឱ្យបានញឹកញាប់ហ្នាំ ! "។



នាងទូលថា "ពរម្ចាស់"។ ហើយនាងក្រមុំព្រមទាំងស្រីបម្រើ វារថយលុះត្រាតែផុតពីទីព្រះគំនាល់ ទើបតម្រង់ទៅកាន់លំនៅអាត្មាវិញ។

At that time, Lady Pov, the owner of the barrage, after hearing that Preah Anuraja camped nearby, promptly ordered her servants to prepare meal and other valuable items as gifts for the lord. When it was ready, Lady Pov, perfumed with the essence and wore beautiful dress leading her servants. She carried a tray of betel leaves and areca nuts with her both hands, wearing a gold and diamond bracelet brightly twinkling with the sun light. She as well as her subordinators kneeled down and saluted to the lord, "Your Lordship, it is my great delight to hear Your Lordship is arriving here and I have prepared some valuable gifts for Your Lordship." "I am so happy that you greet me so kindheartedly in such manner, so I would accept your offer," replied the Lord. Lady Pov handed the items to the lord and said, "May I say farewell to you, Your Lordship." "Yes, you may leave for now but not forget to visit me more often!" smiled and replied the lord. She said, "Yes! I will do, Your Lordship." The maiden as well as her servants duck-walked back until out of the royal audience and returned to their home.

ក្រោយដែលនាងក្រមុំនេះលាចេញផុតទៅ **ព្រះអនុរាជ** ទ្រង់សោយព្រះក្រយាស្ងោយដោយព្រះទ័យរីករាយពន់ពេក។ ព្រះអង្គទ្រង់ស្ញើចព្រះចិន្តានឹងរូបឆោមរបស់កញ្ញា **ពៅ** ដែលល្អឥតខ្ចោះរកនារីណាមកប្រៀបឱ្យស្មើពុំបាន។ ដោយសារធ្នូព្រះកាមទេពបានតម្រង់បាញ់កូនសមកចំដួងហឫទ័យព្រះអង្គ បានជាក្នុងរាត្រីនោះព្រះអង្គទ្រង់ផ្ទំមិនស្កប់ស្កល់សោះ។ លុះព្រឹកព្រាងស្វាងព្រះសុរិយាកាលណា **ព្រះ អនុរាជ** បានត្រាស់បង្គាប់ឱ្យហ្លួងវិចិត្រវោហារជាអាមាត្យទៅស្ដីដណ្ដឹងនារីនោះមកធ្វើជាព្រះស្នំព្រះអង្គ។ គ្រានោះព្រះរាជបម្រើបានប្រញាប់ប្រញាល់រហ័សរហួនតម្រង់ទៅកាន់លំនៅរបស់ **នាងពៅ** ដែលឪពុកម្ដាយនាងបានចែកឋានចោលជាយូរឆ្នាំទៅហើយ។ **នាងពៅ** ក៏រៀបចំកន្លែងដ៏សមគួរដើម្បីទទួលព្រះរាជបម្រើ។ ចំណែកហ្លួងវិចិត្រវោហារក៏ចាប់រ៉ាយរ៉ាប់សព្វសេចក្ដីជម្រាបនាង ព្រមទាំងពោលសរសើរដល់ភ័ព្វវាសនានាងដែលនឹងត្រូវឡើងឋានៈជាព្រះស្នំឯកក្នុងពេលឆាប់ៗនេះ។ នាងក្រមុំគ្មានយល់ទាស់ទេព្រមតាមពាក្យព្រះរាជបម្រើ។ រាល់ល្ងាចព្រះអង្គតែងតែយាងមកក្រសាលខាងក្រៅព្រះពន្លាដែលមានវង់ភ្លេងមហោរីបានប្រគំថ្វាយយ៉ាងពិរោះ ជាទីកំសាន្តព្រះហរទ័យព្រះអង្គ។ គ្រានោះព្រះស្នំឯកថ្មីនេះ បានចូលទៅជិតបម្រើព្រះអង្គជាប្រក្រតី។ មិនយូរប៉ុន្មាន **ព្រះអនុរាជ** ក៏ចាត់ឱ្យពួកជាងរចនាចាត់ចែងសាងបន្ទាយដោយថ្មបាយក្រៀមមានកំផែងពាជាន់ ហើយឱ្យមានទីព្រះលាន និងទីយាមល្បាតព័ទ្ធជុំវិញ។ ចាប់តាំងពីសាងបន្ទាយហើយស្រេច ព្រះអង្គបាននាំពួកបរិវារទៅប្រថាប់ក្នុងទីនោះជាសុខសាន្ត។ **ព្រះអនុរាជ** បានប្រកាសសន្មតឈ្មោះបន្ទាយនេះថា **នគរបាជ័យ** ព្រោះយកតាមព្រះនាមព្រះអង្គដែលអ្នកស្រុកធ្លាប់ស្គាល់ច្បាស់ថា **ព្រះបាទបាជ័យបាអារ្យ**

After the maiden left, Preah Anuraja enjoyed his meal happily. Recognizing the great beauty of Pov, he thought in his mind that no girl on this earth was as beautiful as she was. Falling over heels in love with her, he could not sleep overnight. When it was at dawn, he ordered his officer, Luangvichetra Voha, to offer his proposal to her to be the lord's first lady-in-waiting (snam ek).Immediately after which, his servant went to meet her at her own residence directly since her parents passed away long time ago.

She arranged for a suitable place for him. He told her everything and said she was so fortunate to be named the lord's first lady-in-waiting. She did not deny and accepted the proposal. Every evening, the lord always came out to entertain himself with Mohori orchestra of great symphony. During that time, the new appointed first lady-in-waiting came to serve the lord regularly. Soon after which, the lord ordered the architects and construction workers to build a temple with 3 layers of laterite walls with the royal yard surrounding and compound guarded. After the temple construction project was completed, the lord and his men moved to stay there peacefully and happily. Preah Anuraja named the temple "Nokor Bachey", after his name known by the local residents "Preahbat Bachey Ba A".





តមកព្រះស្នំឯក **ពៅ** មានព្រះគភ៌គម្រប់១០ខែក៏ប្រសូតបានព្រះរាជឱរសមួយអង្គ មានព្រះភ័ក្ត្រប្រិមប្រិយគួរជាអ្នកមានប្រាជ្ញាវាងវៃ។ លុះព្រះរាជកុមារចម្រើនព្រះជន្មបាន ៤ព្រះវស្សា ស្ដេចជាព្រះបិតាក៏ទ្រង់ព្រះតំរិះចង់ឱ្យរាជបុត្រជាអ្នកមានប្រាជ្ញាមួយអង្គ ព្រមទាំងឱ្យស្គាល់វឌ្ឍនធម៌នៃអារ្យប្រទេសនានាផង។ **ព្រះអនុរាជ** ក៏ចាត់ឱ្យរាជបម្រើជូនព្រះរាជបុត្រផ្ញើនៅមហាប្រទេសចិនឱ្យទៅសិក្សា ព្រោះគ្រានោះមានតែប្រទេសចិនមួយទេដែលពូកែខាងវិទ្យាសាស្ត្រជាងប្រទេសឯទៀតៗក្នុងអាស៊ីទ្វីប។ រាជកុមារក្រាបបង្គំលាព្រះបិតា-ព្រះមាតាដោយបានទទួលពរសព្ទសាធុការជាច្រើនផង។



Later first-lady-in-waiting Pov was ten months pregnant and gave birth to a baby boy with charming face and intelligence. At the age of 4, the prince's father, the lord, wanted his child to become a scholar and learn more about the traditions and cultures of other civilized countries. Then, Preah Anuraja arranged for some servants to accompany the prince for his study in China, which was then the only country with most advanced technology in Asia. The prince said farewell to his father and mother, who in turn gave him best wishes for several times.

សំពៅបាននាំយកព្រះរាជបុត្ររបស់ស្ដេចត្រាញ់ បានចេញពីប្រទេសកម្ពុជាឆ្លងកាត់មហាសាគរតម្រង់ទៅដល់ដែនដីចិន។ ក្រោយដែលព្រះរាជបុត្រចេញផុតទៅ ព្រះម្នាង **ពៅ** ពុំរីករាយសោះ ទឹកមុខដែលធ្លាប់តែស្រស់ញញឹម ក៏ប្រែក្លាយទៅជាស្រពោនបីដូចបុប្ផាត្រូវកំដៅព្រះសុរិយាក្នុងគិម្ហរដូវ។ ចំណែក **ព្រះអនុរាជ** ជាស្វាមីក៏ពុំសូវស្រួលព្រះកាយដូចធម្មតាដែរ ចេះតែមានព្រះរោគផ្សេងៗមកញាំញីព្រះអង្គសឹងតែរាល់ថ្ងៃ នាំឱ្យព្រះអង្គមានព្រះកាយពលទន់ខ្សោយជាលំដាប់។ ២ឆ្នាំក្រោយមក ព្រះអង្គក៏សោយទីវង្គតទៅ។ ពីធីបុណ្យរំលាយព្រះសពក៏បានចាត់ចែងឡើងដោយបរិវាររបស់ទ្រង់ មានទាំងស្ដេចត្រាញ់ដែលនៅត្រួតត្រាអាណាខេត្តនានាបានយាងមកជួបជុំជួយញ៉ាំងពិធីបុណ្យនេះយ៉ាងឧឡារិក។ លុះពិធីបុណ្យបានចប់សព្វគ្រប់ហើយ ស្ដេចត្រាញ់ថ្មីដែលត្រូវមកកាន់កាប់ខេត្ត (កំពង់ចាម) នោះបានទៅតាំងទីកន្លែងនៅត្បូងឃ្មុំ ដែលសព្វថ្ងៃបានទៅជាស្រុកជាទីប្រជុំជនមួយយ៉ាងស្កុកស្ដម្ភក្នុងខេត្តកំពង់ចាម ម្ល៉ោះហើយបន្ទាយចាស់ដែល **ព្រះបាទបាជ័យបាអារ្យ** សាងនោះក៏នៅទំនេរគ្មានមនុស្សអ៊ូអរដូចមុនទេ គ្រាន់តែជាបុរាណដ្ឋានសម្រាប់អ្នកទស្សនា។ ចំណែកព្រះស្នំ **ពៅ** ក៏ឈប់នៅក្នុងបន្ទាយនោះដែរ ព្រះនាងត្រឡប់ទៅនៅឯលំនៅចាស់របស់ព្រះនាងវិញ។

The sailing junk took the prince from Cambodia across the ocean to China. After the prince's departure, Preah Maneang Pov, who used to have smiling face, and then turned upset like the flower withers in the summer. And Preah Anuraja also fell ill day after another until he became weaker and weaker. Two year later, the lord passed away, and the cremation ceremony was organized by his servants with the participation of other lords, making it a solemnized event. When the ceremony was over, the new lord (of Kompong Cham province) moved the city to Tbaung Khmum, the prosperous district of today Kompong Cham, and the temple of Preahbat Bachey Ba A was abandoned and became an ancient site for the visitors only. Preah Snom Pov also left the temple and moved to live in her old house.





និយាយពីព្រះរាជបុត្រដែលនៅឯប្រទេសចិន ថ្ងៃមួយទ្រង់បានទទួលដំណឹងថា ព្រះបិតាព្រះមាតាសោយព្រះទីវង្គតអស់ទៅ ហើយបន្ទាយជាកេរ្តិ៍ដំណែលពីព្រះបិតាសាងនោះក៏គេបោះបង់ចោលដែរ ថែមទាំងមានស្តេចត្រាញ់ថ្មីបានតាមព្យាបាទព្រះរាជវង្សនេះផង។ ដំណឹងទាំងនេះជាពាក្យមិនពិតឡើយ គឺពួកនាហ្មឺនចិនគេនាំគ្នានិយាយកុហកទ្រង់ ដើម្បីកុំឱ្យត្រឡប់មកប្រទេសខ្មែរវិញដោយយល់ថា ព្រះអង្គជាកុមារមានប្រាជ្ញាឈ្លាសវៃ ដល់ថ្ងៃក្រោយនឹងក្លាយជាបណ្ឌិតមួយរូបខាងវិទ្យាសាស្ត្រ និងយុទ្ធសាស្ត្រ ត្បិតព្រះអង្គតែងមានព្រះហឫទ័យក្លាហានជានិច្ច។ ទ្រង់ទទួលដំណឹងអកុសលនេះហើយ ព្រះរាជកុមារស្លុតចិន្តាតែខំទប់ព្រះកាយដោយក្តីក្លាហាន ប៉ុន្តែទ្រង់មិនភ្លេចមាតុភូមិរបស់ទ្រង់ឡើយ។ ទ្រង់គិតតែសិក្សាវិជ្ជាឥតហ៊ានសម្រាកផ្តេសផ្តាសទេ។ ក្នុងរវាងព្រះជន២០ព្រះវស្សា ព្រះអង្គបានឡើងឋានៈជាទីប្រឹក្សារបស់បញ្ជាការសឹកនៅប្រទេសចិន។ ផុតពេលប្រជុំប្រឹក្សាទ្រង់តែងព្យាយាមចូលទៅសិក្សាក្នុងសំណាក់អាចារ្យទិសាបាមោក្ខមួយដែលល្បីឈ្មោះជាងគេជាយូរឆ្នាំមកហើយ។

Back to the prince living in China, one day he was told that his parents passed away, and the temple constructed by his father was also abandoned; in addition his family was being harassed by the new lord. The news was just invented by Chinese officials to keep the prince from returning his country because the prince was a talent and would one day become a scholar of science and strategies due to his braveness. The bad news was spread to the prince, but he tried to hold his heart strong, and he never forgot his country. He then tried to learn so hard. At his twenties, the prince became an advisor of a war general in China. After the meeting, he always went to learn more from the most famous teacher for years.

អំឡុង១០ឆ្នាំតមកទៀត ទ្រង់បានជាបណ្ឌិតខាងវិទ្យាសាស្ត្រ ហោរាសាស្ត្រ និងយុទ្ធសាស្ត្រ ហើយបានធ្វើជាទីប្រឹក្សារបស់ព្រះចៅក្រុងចិនទៀតផង។ កិត្តិនាមរបស់ទ្រង់ឡើងល្បីខ្ទរខ្ទាយពេញតែមហាប្រទេសនោះ។ ប្រជាជាតិចិនទាំងប្រុសស្រីនាំគ្នាគោរពរាប់អានព្រះអង្គមិនដែលពោលប្រទូស្តអ្វីឡើយ។ ដូច្នេះហើយបានជាគេសន្មតព្រះនាមព្រះអង្គតាមភាសាចិនថា "**សាមប៉ាវកុង**" ប្រែថា "ព្រឹទ្ធាចារ្យចេះសង្គ្រោះបីយ៉ាង ឬអ្នកប្រាជ្ញបីប្រការ" ។ វេលានោះទ្រង់បានបំពេញករណីកិច្ចនៅក្នុងប្រទេសចិនយ៉ាងពេញកម្លាំងព្រះកាយ ដែលបណ្ដាជនចិនគ្មាននរណាម្នាក់អាចស្មានថាព្រះអង្គហ៊ានលះបង់ប្រទេសចិនឡើយ។ លុះដល់ព្រះជន្មជាង៣០ព្រះវស្សា ទ្រង់បានចូលទៅគាល់ព្រះចៅក្រុងចិនសុំព្រះរាជានុញ្ញាតដើម្បីនឹងធ្វើដំណើរទៅស្រុកក្រៅពិនិត្យអស់កិច្ចការរបស់ទ្រង់។ ព្រះចៅក្រុងចិនក៏ទ្រង់ព្រះអនុញ្ញាតតាមសេចក្ដីសុំរបស់**សាមប៉ាវកុង**។ **សាមប៉ាវកុង** មិនត្រូវការរេហ៍ពលហែហមតាមការពារព្រះអង្គឡើយ។ ទ្រង់ព្រះពស្ត្រ (សំលៀកបំពាក់) ដូចអ្នកស្រែសុទ្ធវិស័យ។ ពួកនាហ្មឺនធំទាំងឡាយនាំគ្នាកោតសរសើរកលល្បិចរបស់ព្រះអង្គដែលចេះក្លែងព្រះកាយដើម្បីសួរសុខទុក្ខរាស្ត្រនៅនិគមជនបទ និងធ្វើការអង្កេតរបស់ពួកអ្នករាជការ តើធ្វើតាមបញ្ញត្តិច្បាប់ដោយចេះត្រាប្រណីប្រជានុរាស្ត្រដែរឬទេ?។ ឱកាសនេះ ជាបរិយាកាសដ៏ទូលាយល្អក្រៃពេក បើកព្រះហឫទ័យឱ្យនឹកដល់ស្រុកកំណើតរបស់ទ្រង់។ លុះស្ដេចយាងដល់កូនភូមិតូចមួយ ទ្រង់បានយាងចូលទៅកាន់ផ្ទះអ្នកស្រុក ហើយទ្រង់ថ្លែងប្រាប់ គេថាព្រះអង្គចេះទាយគន់គូរមើលព្រេងវាសនា ឬមើលអនាគតយ៉ាងឆុត ។ ពួកអ្នកស្រុកកាលបានដឹងដូច្នេះហើយក៏នាំគ្នាមកទាំងហ្វូងមករកសុំទំនាយពីទ្រង់។ ដោយព្រះអង្គម្ចាស់នេះចេះស្ទាត់ខាងហោរាសាស្ត្រមែនទែន ទំនាយទាំងនោះក៏ត្រូវគ្មាន ល្អៀង ។ គេនាំគ្នានិយាយសរសើរពីមាត់មួយទៅមាត់មួយ។

10 years later, he became the scholar of science, horoscope, and strategies, and he was appointed an advisor of Chinese Emperor. The prince's name was so famous throughout the country. All Chinese people respected him and never harmed him. Then he was called "Sambaokong" or "Rescuer of three or the scholar of three". At that time, the prince tried to work for the emperor so devotedly that no one could expect that he would leave this country.

When the prince was over 30 years old, he came to audience with the emperor and asked for his permission to monitor the local civil servants' performance whether they were kind to the people. The Emperor granted the permission to Sambaokong. Samboakong needed no any guards or servants to accompany him. The main officials praised the prince's strategy to disguise him a very simple person to observe the civil servant's work. It was a special time to make the prince become homesick of his country. When the prince arrived in a small village, he came to a house and told the owner that he was very skillful at telling the fortune. As soon as his reputation was known to the local residents, they together came to ask the prediction from the prince. With his deep insight of horoscope, his prediction occurred as his words. His name was talked among the locals.



រាត្រីកាលចូលមកដល់ ទ្រង់បានផ្ទំនៅក្នុងខ្ទមតូចជាមួយនឹងតាចាស់ម្នាក់ ហើយទ្រង់ព្រះតំរិះថា "ព្រះមាតាបិតាអញសុគតអស់ទៅហើយ ប៉ុន្តែអញត្រូវតែត្រឡប់ទៅស្រុកវិញឱ្យឃើញមុខប្រជាជាតិខ្មែរជាជនរួមជាតិ និងជាកេរ្តិ៍ដំណែលព្រះបិតាអញវិញ"។ ដោយព្រះអង្គនឹកដល់មាតុភូមិពេកក៏ទ្រង់ជ្រប់ព្រះភ័ក្ត្រស្រពាប់ស្រពោន នឹកទៅឃើញថា មិនដឹងប្រទេសកម្ពុជានោះជាប្រទេសបែបណាទេ សូម្បីតែវឌ្ឍនធម៌ខ្មែរក៏ពុំជ្រាបយ៉ាងដូចម្តេចផង ព្រោះទ្រង់ចេញចាកនៅក្មេងណាស់ មិនទាន់ចាំព្រះភ័ក្ត្រព្រះបិតា-មាតាច្បាស់នៅឡើយ។ ដោយទ្រង់ព្រះតំរិះសព្វគ្រប់ដូច្នេះហើយបានជាមហាបណ្ឌិតនេះលួចរត់ចេញពីប្រទេសចិនមិនឱ្យជនណាម្នាក់បានដឹងបន្តិចសោះ។ លុះទ្រង់បានមកដល់ប្រទេសខ្មែរហើយ ទ្រង់បានលាក់ព្រះកាយនៅភូមិតូចតាចដើម្បីខំហាត់រៀនភាសាខ្មែរ។ ដោយព្រះអង្គមានព្រះជាតិជាខ្មែរស្រាប់ មិនយូរប៉ុន្មានទ្រង់ក៏បានចេះភាសាខ្មែរស្ទាត់ដូចខ្មែរធម្មតាដែរ ហើយបានប្រាប់ឈ្មោះអ្នកភូមិនោះថា "**ព្រហ្ម**" ដើម្បីឱ្យគេជឿថាពិតជាខ្មែរមែន។ ៧ខែក្រោយមក **ព្រហ្ម** ក៏បានទៅដល់ ស្រុក (កំពង់ចាម) តែទ្រង់ឥតមាននឹកនាស៊ើបសួររកញាតិវង្សអ្វីបន្តិចទេ ត្បិតទ្រង់ ជ្រាបថាទ្រង់បានខ្ចាត់ព្រាត់ប្រាសគ្នាអស់ទៅហើយ និងដោយខ្លាចអំណាចស្តេចត្រាញ់ ថ្មីផង។ នាយ **ព្រហ្ម** បានទៅសុំស្នាក់នៅនឹងផ្ទះយាយចាស់ម្នាក់ដែលគាត់បាត់ញាតិសន្តានអស់នៅត្រឹមតែបាវព្រាវពីរបីនាក់ប៉ុណ្ណោះ។ យាយនោះ ទោះបីគាត់មានអាយុជាង៥០ឆ្នាំទៅហើយក្តី តែរូបគាត់នៅតែស្អាតបាតស្បែកពុំទាន់ជ្រីវជ្រួញ សក់ពុំទាន់ស្កូវ ធ្មេញក៏ពុំទាន់បាក់នៅឡើយ។ ដោយសារយាយជួយឧបត្ថម្ភដោយស្មោះ ក៏បណ្តាលឱ្យព្រះអង្គម្ចាស់ **ព្រហ្ម** គួចចិត្តប្រតិព័ទ្ធលើរូបដូនចាស់នេះជាខ្លាំងបានពឹងអ្នកជិតខាងឱ្យគេទៅស្តីដណ្តឹងយាយនោះធ្វើជាប្រពន្ធ។ យាយនេះក៏យល់ព្រមឥតប្រកែកឡើយ ព្រោះគាត់មិនចង់នៅតែម្នាក់ឯងនាំឱ្យនឹកដល់កូនដែលឃ្លាតចាកទៅមិនដឹងជាស្លាប់ឬរស់។ ដូនចាស់ និងតាកម្លោះក៏នៅរួមសុខរួមទុក្ខជាមួយគ្នារហូតមក។

When the night fell, the prince stayed in a house of an old man and thought, "Both my parents passed away, but I must return to my country to see my Khmer people and my father's heritage." Then out of being homesick of his country, he looked sad in his face because he knew that he had no idea about his country,even the civilization of his country because when he left his country he was so young that he could not even remember his parent's face.



After thinking it over, the prince left China, which was known to no Chinese people. When he arrived in Cambodia, he hid in a small village and started learning Khmer. Due to his Khmer origin, it took him a short time to learn how to speak Khmer. Then he told the other to call him "Prom" to make them believe that he was a real Khmer resident. 7 months later, he arrived in Kompong Cham province, but he not wished to find his relatives since he knew that they were separated from each other and feared the power of the new lord. Later, he asked for a stay at an old lady's house. The old lady lost her relatives, and lived with only a few servants. Though she was an old lady of over 50 years, but her beauty still stayed, her skin not wrinkle, her hair not white, and her teeth not lost. Because of her honest support to the prince, the prince Prom fell in love with her and asked the neighbor to propose an engagement to the lady for him. The old lady accepted without denial because she did not want to live missing her son leaving her without knowledge of whether he was alive. The old lady and the young bachelor lived together happily ever since.

ថ្ងៃមួយយាយកើតក្ដីអផ្សុកក៏ឱ្យតាវាយលេខគន់គូររកកូនប្រុសគាត់ដែលឃ្លាតទៅស្រុកចិនតាំងពីអាយុបាន៤ឆ្នាំ។ តាស្ដាប់សំដីយាយចប់នឹកឆ្ងល់ពន់ពេកក៏សួរថា "នែ៎យាយ ! កូនយាយចាកចេញទៅពីឆ្នាំណា? តើប្ដីយាយមុនជាអ្នកណា ! ?" យាយឱនមុខចុះសម្រក់ទឹកភ្នែកនិយាយទាំងអួលដើមកថា "ឱតាអើយ ! កូនប្រុសខ្ញុំឃ្លាតចាកពីខ្ញុំទៅជាង៣០ឆ្នាំហើយ ឯប្ដីខ្ញុំពីមុននោះ គឺជាស្ដេចត្រាញ់មួយអង្គត្រួតត្រានៅក្នុងខេត្តនេះ បានទាំងសាងបន្ទាយថ្មមួយយ៉ាងល្អប្រណិតទុកនៅដល់សព្វថ្ងៃនេះ ផង ។ តាមើលចុះ ទីបឹងក្បែរផ្ទះយើងនេះហើយដែលព្រះស្វាមីធ្លាប់នាំខ្ញុំជិះទូកកំសាន្តរាល់ល្ងាច។ ព្រះអង្គបានឱ្យឈ្មោះបឹងនេះថា **ទន្លេអុំ** គឺជាទន្លេសម្រាប់អុំទូកលេង"។ នាយ **ព្រហ្ម** ស្ដាប់ចប់ក៏ស្លុតស្មារតី ហើយឱនក្បាលលុតជង្គង់ចុះលើកដៃទាំងពីរសំពះប្រណម្យនៅចំពោះមុខយាយ។ ចំណែកយាយទៅជាស្រឡាំងកាំងហាស្ដីមិនរួច។ នាយ **ព្រហ្ម** និយាយថា "ឱអ្នកមានគុណកូនអើយ ! សូមឱ្យកូនសុំខមាទោសយ៉ាងធ្ងន់ធ្ងរនេះទៅចុះ គឺថា ខ្ញុំនេះហើយដែលជាកូនបានឃ្លាតចាកទៅប្រទេសចិនតាំងពីអាយុ៤ឆ្នាំ ហើយកូនបានឮគេនិយាយថា ព្រះមាតាបិតាសុគតអស់ទៅហើយ មិននឹកស្មានថា ព្រះមាតានៅគង់ព្រះជន្មដូច្នេះសោះ។ យាយ **ទៅ** ឮហើយក៏ស្ទុះឱបកូនតែហាមាត់ថាអ្វីមួយម៉ាត់ក៏ពុំរួច។ នាយ **ព្រហ្ម** និយាយទៀតថា "បើព្រះមាតាចង់ដាក់ទណ្ឌកម្មកូនយ៉ាងណា ក៏កូនសុខចិត្តរ៉ាប់រងតាមទាំងអស់ សូមមានប្រសាសន៍មកចុះ" យាយប្រាប់ថា "បើកូនឯងចង់ដោះចាកទោសល្មើសនេះ ចូរកូនធ្វើតាមពាក្យម្ដាយចុះ បើកាលណាម្ដាយស្លាប់ទៅ ចូរកូនសាងចេតិយមួយនៅក្នុងបន្ទាយ **នគរធាជ័យ** ហើយយកសពម្ដាយទៅដាក់ក្នុងនោះ និងសាងព្រះពុទ្ធ៤អង្គដឹកលក់ក្បែរសពម្ដាយនោះផង កាលណាកូនទៀបស្លាប់ទៅទៀតត្រូវផ្ដាំឱ្យគេជាសិស្សគណសាងដោយថ្មជារូបកូន ដៃសំពះប្រណម្យទៅរកចេតិយម្ដាយ លុះត្រាតែផុតសាសនាព្រះសមណគោតម។ បើកូនធ្វើយ៉ាងនេះ ពៀរវេរាជាកំហុសនឹងបានដោះផុតជាមិនខាន"។ នាយ **ព្រហ្ម** ឱនក្បាលទទួលថា "សូមព្រះមាតាកុំព្រួយ ! កូននឹងធ្វើតាមបណ្ដាំមាតាទាំងអស់" ។

One day, with her boredom, the old lady asked her young husband to predict about her son who left her since he was four years old. When the old lady finished her words, the young prince curiously wondered and asked,"When did your son leave you? Who was your late-husband?"



The old lady turned her face down and replied in tear, "My dear, my son has left me for more than 30 years, and my late-husband was a lord of this province who left a beautiful stone temple for me which still stands today. And you can see the lake near my house. It is the place where my late-husband and I used to row the boat every evening, and he called the lake "Tonle Om". It means the river for rowing boat." He was shocked after hearing her answer, kneeled down, and prayed to the old lady. The old lady was surprised at his action. "My dear mother, please forgive my unpardoned mistake, it is me who have left you since I was 4 years old, and I was informed that you and father passed away, without knowing that you are still alive. Elderly Pov then hurried to hold him and spoke nothing. "Please give me punishment in whatever form you feel like Mom," continued Prom. "If you want to atone for all these sins, you must follow my advice. When I die, you must build a stupa in the temple compound and store four Buddha statues and when you die, tell your followers to build a statue of yours praying me until the end of Buddha's era. If you can follow all my advice, you will be able to atone for your bad sins," said the lady. Prom lowered his head and accepted, "Please don't worry, I will follow all your advice."



ចាប់តាំងពីពេលនោះមក ជនទាំងពីរក៏រស់នៅជាមួយគ្នាតាមឋានៈជាកូន និងម្ដាយរហូតមក។ បានប្រហែលពីរឆ្នាំយាយ **ពៅ** ក៏ស្លាប់ទៅ។ កូនប្រុសនោះក៏ចាត់ចែងសាងចេតិយបញ្ចុះសពម្ដាយ ព្រមទាំងសាងរូបព្រះពុទ្ធ៤អង្គដឹកលំជុំវិញចេតិយនោះដែលសព្វថ្ងៃគេឃើញមានសង់វិហារមួយគ្របលើចេតិយតូចនោះផង។ មិនយូរប៉ុន្មានដោយកូននឹកអាល័យម្ដាយពេកតា **ព្រហ្ម** ក៏មានជំងឺធ្ងន់ស្លាប់ទៅដែរ តែមុននឹងស្លាប់គាត់បានផ្ដាំពពួកសិស្សគណឱ្យសាងរូបថ្មជាជំនួសខ្លួនអង្គុយបែរមុខទៅខាងលិចសំពះតម្រង់ទៅរកសពម្ដាយដែលគេឃើញរូបនោះនៅរហូតដល់សព្វថ្ងៃ។



និយាយពីព្រះចៅក្រុងចិន កាលបើបាត់បណ្ឌិត **សាមប៉ាវកុង** ហើយក៏ចាត់ឱ្យនាហ្មឺនជាច្រើនរូបស៊ើបសួររក មាននាហ្មឺនម្នាក់បានធ្វើដំណើររហូតមកដល់ប្រទេសខ្មែរត្បិតគេដឹងថា បណ្ឌិតនេះមានជាតិកំណើតជាខ្មែរ។ ប៉ុន្តែទំរាំនាហ្មឺននេះបានមកដល់ស្រុកខ្មែរ បណ្ឌិត **ព្រហ្ម** បានទទួលអនិច្ចកម្មទៅហើយ។ នាហ្មឺននោះបានធ្វើគារវៈកិច្ចចំពោះរូបថ្មនោះ ហើយបានចារឹកឈ្មោះបដិមាករនេះជាអក្សរចិនថា "**សាមប៉ាវកុង**" ទុករហូតមក។

Since then, they lived as a mother and a son. Only 2 years later, elderly Pov passed away. The prince started the construction of a stupa to burry his mother and stored 4 Buddha statues surrounding the stupa which now is seen covered by a temple. Sooner or later, due to missing his mother, Ta Prom, fell seriously ill and passed away. But before his death, he told his students to build a stone statue of him sitting and praying the stupa as it is seen nowadays.

Talking about Chinese Emperor, while the long absence of Sambaokong, he ordered his men to find him, and one of them traveled to Cambodia because he knew that the Khmer-born scholar returned to his country. However, it was too late when he arrived because Prom the scholar already passed away. The servant showed his respect to the statue and wrote in Chinese letters on the statue "Sambaokong" lasting since that time.



សព្វថ្ងៃនេះ  អ្នកស្រុកបានសង់គុហារមួយដោយបាយអគ្រេបពីលើបដិមាករនេះ។ រាល់ពេលបុណ្យខ្មែរ ឬបុណ្យចិនមានមនុស្សជាច្រើនបានចូលទៅអុជធូបទៀនបូជាដល់បដិមាករនោះ ហើយមានជនខ្លះទៀតបានធ្វើជាកិច្ចបួលស្នែងក្របី  និងបួលដោយរលាក់ចង្កឹះហើយពោលថាឆុតពូកែណាស់ ទុកជាមានគ្រោះថ្នាក់យ៉ាងណា ឬចង់ដឹងពីផលរបរអ្វីមួយគេអាចទាយត្រូវភ្លាម។

មិនតែប៉ុណ្ណោះ កាលពីរវាងព.ស ២៤៧០ប្លាយ មានពួកអ្នកជំនួញនៅក្រុងកំពង់ចាម បាននាំគ្នាទៅបង្វិលរូបថ្មនោះឱ្យបែរមុខទៅទិសខាងត្បូងឱ្យត្រូវតាមទំនងផ្លូវចូល តែដល់បែរមុខរូបតា **ព្រហ្ម** នេះទៅ អ្នកស្រុកនេះក៏កើតជំងឺស្លាប់ជាច្រើន។ កាលណោះខ្មោចតា **ព្រហ្ម** បានចូលរូបយាយ **ដាម** ជារូបបញ្ចាន់នៅភូមិសណ្ដាន់ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានប្រាប់អ្នកស្រុកថា "កុំបែរមុខរូបអញទៅឯណា អញត្រូវតែបែរមុខទៅទិសខាងលិចសំពះឆ្ពោះទៅចេតិយខ្មោចម្ដាយអញ"។ ក្រោយពីខ្មោចតា **ព្រហ្ម** ចូលមកនោះ អ្នកស្រុកគេបំបែរមុខរូបតា **ព្រហ្ម** ទៅទិសខាងលិចដូចដើមវិញនៅរហូតដល់សព្វថ្ងៃ។ **ចប់**

Today, the residents have built a shrine covering the statue. Every Khmer or Chinese New Year, there are a lot of visitors coming and lighting the incenses to pay homage to the statue, and some use buffalo's horn or some use chopsticks to predict by saying "Occurring as expected", so they can predict their accident or anything correctly. About 2470 of Buddha era, some vendors in Kompong Cham province relocated the statue in direction facing the gateway, but after changing the direction, most the residents fell ill and several died. Then Ta Prom ghost used elderly Dam in Sandan village, Ampel commune, Kompong Siem district, Kompong Cham province to send his message "Don't change the direction of my statue. I must pray to the west for the stupa of my mother." After the event, the residents located the statue to its original direction.

**The End**